ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ១៣ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៩*

# សេចក្តីជូនដំណឹង

## សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)

កាលពីថ្ងៃអង្គារ ១៣ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៩, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកស្រី Ophélie BOURHIS នាយកទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានសម្រាប់គម្រោងចំនួន ២ ដែលមានទឹកប្រាក់ឥណទានសម្បទានសរុបចំនួន ១១៨ លានអឺរ៉ូ (ប្រមាណជា ១២១,៣២ លានដុល្លារអាមេរិក) ។ កិច្ចចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាននេះ គឺជាការចុះហត្ថលេខាផ្លាស់ប្តូរអត្ថបទនៃកិច្ចព្រមព្រៀង (Cross Signing) គ្នាទៅវិញទៅមក ។ កិច្ចព្រមព្រៀងទាំង ២ នេះ មានដូចខាងក្រោម÷

***១. ឥណទានសម្បទានចំនួន ១០០ លានអឺរ៉ូ (ប្រមាណជា ១០១,៤ លានដុល្លារអាមេរិក)សម្រាប់គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដំណាក់កាលទី២÷***

តាមរយៈកិច្ចព្រមព្រៀងនេះ, ទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD) នឹងផ្តល់ឥណទានសម្បទានបន្ថែម ចំនួន ១០០ លានអឺរ៉ូ សម្រាប់អនុវត្តគម្រោងនេះបន្តពីគម្រោងជំហានទី ១ ។ គម្រោងនេះមានទិសដៅ÷ ១. សាងសង់ស្ថានីយ៍បូមទឹក ដែលមានសមត្ថភាពផលិតទឹកស្អាតបាន ១៩៥ ០០០ ម$^{៣}$/ថ្ងៃ, ២. បំពាក់បំពង់មេនាំទឹកស្អាត, បំពង់ចែកចាយ និងសម្ភារៈតភ្ជាប់បំពង់ និង ៣. ត្រួតពិនិត្យការងារសាងសង់ និងគាំទ្រដល់ការពង្រឹងសមត្ថភាពមន្ត្រីរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញលើការងារលទ្ធកម្ម និងតម្លើងបណ្តាញចែកចាយទឹក ។

***២. ឥណទានសម្បទានចំនួន ១៨ លានអឺរ៉ូ (ប្រមាណជា ១៩,៩២ លានដុល្លារអាមេរិក) សម្រាប់គម្រោងអភិវឌ្ឍន៍ជំនាញសម្រាប់ការប្រកួតប្រជែង÷***

តាមរយៈកិច្ចព្រមព្រៀងនេះ, ទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD) នឹងផ្តល់ឥណទានចំនួន ១៨ លានអឺរ៉ូ សម្រាប់ធ្វើសហហិរញ្ញប្បទានជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជូនរាជរដ្ឋាភិបាលកម្ពុជា សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ជំនាញសម្រាប់ការប្រកួតប្រជែង ដែលមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាភ្នាក់ងារប្រតិបត្តិគម្រោង ហើយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាភ្នាក់ងារអនុវត្តគម្រោង ។ គម្រោងនេះ មានទិសដៅ÷ ១. កែលម្អ និងលើកកម្ពស់គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកម្រិតក្រោយមធ្យមសិក្សា, ២. លើកកម្ពស់ការសិក្សាផង និងធ្វើការផង តាមបណ្តាឧស្សាហកម្មនានា និង ៣. ពង្រឹងយន្តការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ឲ្យប្រកបដោយនវានុវត្តន៍ ។

ការផ្តល់ហិរញ្ញប្បទានដល់គម្រោងទាំងពីរខាងលើនេះ គឺបានឆ្លើយតបយ៉ាងជាក់ច្បាស់ទៅនឹងសេចក្តីត្រូវការជាអាទិភាពរាជរដ្ឋាភិបាលកម្ពុជា ក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព និងសហគ្រិនភាព និងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជនតាមរយៈការពង្រឹកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត និងការបំពាក់ប្រព័ន្ធចែកចាយ និងផ្គត់ផ្គង់ទឹកស្អាត ។ ហិរញ្ញប្បទានដ៏ថ្លៃថ្លាពីរដ្ឋាភិបាលសាធារណរដ្ឋបារាំងនេះ នឹងរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា សំដៅជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង បង្កើតការងារ បែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន និងបង្កើនប្រសិទ្ធិភាពនៃការវិនិយោគដែលជាមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់ ។

សូមគូសបញ្ជាក់ថា ហិរញ្ញប្បទានសហប្រតិបត្តិការពីសាធារណរដ្ឋបារាំង តាមរយៈទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) ផ្តោតទៅលើវិស័យអាទិភាពសំខាន់ៗ រួមមាន÷ អភិវឌ្ឍន៍កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ, បណ្តុះបណ្តាលជំនាញ, គាំទ្រវិស័យផលិតកម្ម,ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ គិតចាប់ពីឆ្នាំ ១៩៩៣ ដល់ខែ ធ្នូ ឆ្នាំ ២០១៩ សាធារណរដ្ឋបារាំងបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការចំនួនប្រមាណ ៨០២ លានអឺរ៉ូ ក្នុងនោះមាន÷ ហិរញ្ញប្បទានឥតសំណងចំនួន ២០១ លានអឺរ៉ូ, ឥណទានសម្បទាន “Sovereign Loan” ចំនួន ៤៣៤ លានអឺរ៉ូ និងឥណទានគ្មានការធានាពីរដ្ឋ “Non Sovereign loan” ចំនួន ១៦៧ លានអឺរ៉ូ ។